ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
លេខ : ០៣ សរណន

# សារាចរណែនាំ

## ស្តីពី

## ការពង្រឹងការងារនៅស្ថានតំណាងកម្ពុជានៅបរទេស

កន្លងមក រាជរដ្ឋាភិបាលបានសង្កេតឃើញថា ស្ថានតំណាងកម្ពុជានៅបរទេសបានខិតខំយ៉ាងសកម្មក្នុងការបំពេញភារកិច្ចជូនជាតិមាតុភូមិ ដោយប្រធាន មន្ត្រី និងបុគ្គលិកទាំងអស់ក្នុងស្ថានតំណាង សហការគ្នាយ៉ាងល្អប្រសើរក្នុងការដោះស្រាយចាត់ចែងកិច្ចការពហុវិស័យ ។ ទន្ទឹមនឹងនេះក៏នៅមានបាតុភាពខ្លះទាក់ទងនឹងការមិនស៊ីសង្វាក់គ្នាក្នុងការបំពេញភារកិច្ចនៅក្នុងស្ថានតំណាងកម្ពុជា មួយចំនួននៅបរទេស ដែលជាអាទិ៍ ទីប្រឹក្សា ឬអនុព័ន្ធផ្នែកជំនាញខ្លះបានធ្វើកិច្ចការ និងរាយការណ៍អំពីសកម្មភាពការងាររបស់ខ្លួនត្រង់មកក្រសួងសាមី ដោយពុំឆ្លងតាមឯកអគ្គរាជទូត និងក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិឡើយ ជាហេតុនាំឱ្យឯកអគ្គរាជទូតដែលជាតំណាងឱ្យរាជរដ្ឋាភិបាលនៅតាមប្រទេសនិមួយៗនោះ ពុំអាចមានពត៌មានអំពីសកម្មភាពរបស់ផ្នែកជំនាញទាំងនោះបានឡើយ ។

ដើម្បីបង្កើនប្រសិទ្ធភាពក្នុងការងាររបស់ស្ថានតំណាងការទូតរបស់កម្ពុជាយើងនៅបរទេស រាជរដ្ឋាភិបាលសូមធ្វើការណែនាំបន្ថែមដូចតទៅ :

១-ឯកអគ្គរាជទូត និងអគ្គកុងស៊ុល ដែលជាតំណាងរបស់រាជរដ្ឋាភិបាលនៅបរទេសត្រូវទទួលខុសត្រូវរួមលើគ្រប់ការងារទាំងអស់ទាក់ទងនឹងប្រទេសដែលខ្លួនស្នាក់នៅ និងទទួលរ៉ាប់រង ។

២-គ្រប់ទីប្រឹក្សា និងអនុព័ន្ធពាណិជ្ជកម្ម យោធា និងនគរបាលជាតិអមស្ថានទូតកម្ពុជានៅបរទេសទាំងអស់ត្រូវធ្វើរបាយការណ៍អំពីសកម្មភាពការងាររបស់ខ្លួនជូនក្រសួង ស្ថានប័នសាមី ដោយត្រូវឆ្លងតាមរយៈឯកអគ្គរាជទូត និងក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ ។

៣-គ្រប់គណៈប្រតិភូរបស់រាជរដ្ឋាភិបាល មុននឹងចេញទៅធ្វើទស្សនកិច្ច ឬបំពេញបេសកកម្មនៅប្រទេសណាមួយត្រូវផ្តល់ពត៌មានឱ្យក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ និងស្ថានឯកអគ្គរាជទូត

ឬអគ្គកុងស៊ុលប្រចាំនៅប្រទេសនោះបានជ្រាប និងសហការជួយបង្កលក្ខណៈឱ្យដំណើរទស្សនកិច្ច ឬការបំពេញបេសកកម្មទទួលបានជោគជ័យ ។

ទទួលបានសារាចរណែនាំនេះ ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ ក្រសួងមហាផ្ទៃ ក្រសួងការពារជាតិ ក្រសួងពាណិជ្ជកម្ម និងក្រសួងស្ថាប័នពាក់ព័ន្ធ ត្រូវធ្វើការផ្សព្វផ្សាយ និងចាត់ចែងអនុវត្តឱ្យទទួលបានលទ្ធផលជាវិជ្ជមាន ។

រាជធានីភ្នំពេញ ថ្ងៃទី ១៨ ខែ មេសា ឆ្នាំ ២០០៦

នាយករដ្ឋមន្ត្រី

ហ៊ុន សែន

**ចំលងជូន**

- -ក្រសួងព្រះបរមរាជវាំង
- -អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- -អគ្គលេខាធិការដ្ឋានរដ្ឋសភា
- -ក្រសួង រដ្ឋលេខាធិការដ្ឋាន និងស្ថាប័ន
- -ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- -ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
- -អគ្គលេខាធិការដ្ឋានរាជរដ្ឋាភិបាល
- -រាជកិច្ច ✓
- -ឯកសារ-កាលប្បវត្តិ